## ២.៧ ការបន្តការអភិវឌ្ឍគ្រូបង្រៀន

### វត្ថុបំណង និង យុត្តិកម្ម

វត្ថុបំណងចម្បងរបស់កម្មវិធីនេះ គឺធានាការផ្តល់គ្រូបង្រៀនកំរិតអប់រំមូលដ្ឋាន និងគ្រូបង្រៀនកំរិតបរិញ្ញាប័ត្រប្រកបដោយប្រសិទ្ធភាព ដើម្បីឆ្លើយតបទៅនឹងការពង្រីកប្រព័ន្ធការបណ្តុះបណ្តាល និងការពង្រីកសមត្ថភាពអ្នកគ្រប់គ្រងសាលាគរុកោសល្យ និងអ្នកគ្រប់គ្រងអប់រំ គ្រូឧទ្ទេសនៅវិទ្យាស្ថានជាតិអប់រំ នាយកសាលារៀន និងមន្ត្រីអប់រំសំខាន់ៗផ្សេងទៀត ។ វត្ថុបំណងទី ២ គឺធានាថា គរុសិស្ស-គរុនិស្សិតនៅសាលាគរុកោសល្យ និងវិទ្យាស្ថានជាតិអប់រំ ព្រមទាំងការដាក់ពង្រាយគ្រូចេញថ្មី ឆ្លើយតបទៅនឹងកំណើនតម្រូវការនៅតំបន់ជនបទ តំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក តាមរយៈការជ្រើសរើសគរុសិស្ស-គរុនិស្សិតថ្មីពីតំបន់ទាំងនោះ និងតំបន់ជនជាតិភាគតិច ។ វត្ថុបំណងទី ៣ គឺកែលំអគុណភាពនៃការបង្រៀន តាមរយៈការពង្រីកការធ្វើវិក្រឹតការគ្រូបង្រៀន ។

### ចំណុចដៅ និងអាំងឌីកាទ័រចម្បងៗ

- ជ្រើសរើសគរុសិស្ស-គរុនិស្សិតថ្មីចំនួន ៥,០០០ នាក់ក្នុងមួយឆ្នាំ ចូលរៀននៅសាលាគរុកោសល្យដែលក្នុងនោះយ៉ាងតិច ៣០% មកពីតំបន់ជនបទ តំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក ។
- បង្កើនសមត្ថភាពគ្រូបឋមសិក្សាចំនួន ៣,០០០ នាក់ អោយក្លាយជាគ្រូបង្រៀនកម្រិតអប់រំមូលដ្ឋាន តាមរយៈការបំប៉ននៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគទាំង ៦ នៅត្រឹមឆ្នាំ ២០១០ ។

### យុទ្ធសាស្ត្រ និង វិសាលភាព

ប្រព័ន្ធអភិវឌ្ឍការបណ្តុះបណ្តាល និងវិក្រឹតការដែលមានលក្ខណៈឆ្លើយតប និងមានភាពទន់ភ្លន់ មានសារៈសំខាន់ណាស់សម្រាប់ធានាអោយមានការចូលរៀនដោយសមធម៌នៅបឋមសិក្សា និងមធ្យមសិក្សា ។ ការផ្គូរផ្គងរវាងការផ្គត់ផ្គង់ និងតម្រូវការគ្រូបង្រៀនដែលបានបណ្តុះបណ្តាល និងមានគុណភាព ទាមទារឱ្យមានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយនាយកដ្ឋានបុគ្គលិក និងអាជ្ញាធរអប់រំខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ ។ នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ក៏ត្រូវពិនិត្យឡើងវិញផងដែរអំពីយុទ្ធសាស្ត្រធ្វើសនិទានកម្មសាលាគរុកោសល្យ ដូចជាសំណើស្តីពីការច្របាច់សាលាគរុកោសល្យ និង វិក្រឹតការខេត្ត-ក្រុង និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគទាំង ៦ បញ្ចូលគ្នា ព្រមទាំងពិចារណាអំពីកំរិតនៃថវិកាដំណើរការរបស់គ្រឹះស្ថានទាំងនោះ ។

កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន នឹងគ្របដណ្តប់ទៅលើសាលាគរុកោសល្យ និង វិក្រឹតការខេត្ត-ក្រុងទាំង ១៨ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគទាំង ៦ សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈឹម និងវិទ្យាស្ថានជាតិអប់រំ ។ កម្មវិធីការបន្តការអភិវឌ្ឍគ្រូបង្រៀន និងការធ្វើវិក្រឹតការគ្រូ នឹងគ្របដណ្តប់ទៅលើក្រុមមុខសញ្ញាដែលបច្ចុប្បន្នជាបុគ្គលិកបង្រៀន ដោយសង្កត់ធ្ងន់ទៅលើការបំប៉នបន្ថែមគ្រូបឋមសិក្សាគ្រូអប់រំមូលដ្ឋានសម្រាប់ទៅបង្រៀននៅសាលាមធ្យមសិក្សាបឋមភូមិ ។ ការបណ្តុះបណ្តាលការងារគ្រប់គ្រងត្រូវធ្វើជាបន្តទៀត

ដោយផ្ដោតទៅលើនាយកសាលារៀន ក៏ប៉ុន្តែត្រូវពង្រីកទៅដល់មន្ត្រីគ្រប់គ្រងអប់រំនៅគ្រប់កំរិតផងដែរ ។ ចំណាយសម្រាប់កម្មវិធីនេះ គឺសម្រាប់ការបន្តវិក្រឹតការគ្រូបង្រៀន ដោយបង្កើនការផ្ទេរសិទ្ធិគ្រប់គ្រងទៅអោយខេត្ត/ក្រុង ។

**កម្មវិធី និងសកម្មភាពចម្បង១**

**១- ថវិកាដំណើរការសាលាគរុកោសល្យទាំង ២៥**

- ផ្តល់ថវិកាដំណើរការប្រចាំឆ្នាំដល់សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈឹម សាលាគរុកោសល្យ និង វិក្រឹតការខេត្ត-ក្រុងទាំង ១៨ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគទាំង ៦ មជ្ឈមណ្ឌលធនធានថ្មីទាំង ៦ សំដៅកែលំអគុណភាព និងប្រសិទ្ធភាពនៃកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន ។ អាទិភាពថ្មីមួយសម្រាប់សាលាគរុកោសល្យ គឺការបណ្តុះបណ្តាលគ្រូកំរិតមូលដ្ឋាន ដើម្បីឆ្លើយតបប្រកបដោយភាពទន់ភ្លន់ទៅនឹងការប្រែប្រួលការចូលរៀននៅបណ្តាឆ្នាំខាងមុខនេះ ។
- ដាក់ចេញនូវគោលការណ៍សម្រាប់កម្មវិធីសាលាកុមារមេត្រី (CFS) និងកម្មវិធីសម្រាប់កុមារត្រៀមចូលរៀនបឋមសិក្សា (SRP) ទៅក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន ព្រមទាំងអនុវត្តនៅគ្រប់សាលាគរុកោសល្យ និង វិក្រឹតការខេត្ត-ក្រុង ។
- ផ្តល់វគ្គសិក្សាស្តីពីការយល់ដឹងពីមេរោគហ៊ីវ/ជម្ងឺអេដស៍ ការផ្តល់សៀវភៅសិក្សា និងសៀវភៅណែនាំគ្រូសម្រាប់គរុសិស្សថ្មីទាំងអស់[១] ។

**២- ការអភិវឌ្ឍមន្ត្រីអប់រំនៅសាលាគរុកោសល្យ ខេត្ត-ក្រុង**

- បង្កើនសមត្ថភាពបុគ្គលិកនៅសាលាគរុកោសល្យទាំងអស់ រួមមានការបំប៉នគ្រូឧទ្ទេស តាមរយៈកម្មវិធីអភិវឌ្ឍន៍បុគ្គលិកនៅសាលាគរុកោសល្យ ។ កម្មវិធីនេះនឹងផ្តល់លិខិតបញ្ជាក់ជាផ្លូវការ ដែលជាមូលដ្ឋានគ្រឹះសម្រាប់អភិវឌ្ឍឱ្យបានឆាប់រហ័សនូវប្រព័ន្ធបណ្តុះបណ្តាលគ្រូថ្នាក់ជាតិ ។

**៣- កម្មវិធីអភិវឌ្ឍការគ្រប់គ្រងអប់រំ**

- ផ្តល់ឱ្យនាយកសាលាបឋមសិក្សា និងមធ្យមសិក្សា នូវជំនាញនានាដើម្បីអនុវត្តការដឹកនាំអោយបានសកម្ម និង ទទួលខុសត្រូវក្នុងការអនុវត្តវិធានការនានា និងគ្រប់គ្រងធនធានប្រកបដោយប្រសិទ្ធភាព និងគុណភាព តាមរយៈកម្មវិធីបណ្តុះបណ្តាលការគ្រប់គ្រងអប់រំ ។ ការបណ្តុះបណ្តាលនេះ ត្រូវផ្តល់តាមរយៈកម្មវិធីបណ្តុះបណ្តាលពីចម្ងាយ និងសិក្ខាសាលានៅនឹងកន្លែងការងារ ក្នុងឆ្នាំសិក្សា ។ ការផ្តល់លិខិតបញ្ជាក់លើមុខវិជ្ជាជីវៈដែលផ្សារភ្ជាប់ទៅនឹងកម្មវិធីនេះ ស្ថិតក្នុងការពិនិត្យឡើងវិញ ។ កម្មវិធីនេះនឹងត្រូវពិចារណាដើម្បីពង្រីកទៅដល់មន្ត្រីអប់រំដទៃទៀត ។

---

[១] *មានការគាំទ្រតាមរយៈគណៈកម្មការអន្តរនាយកដ្ឋានស្តីពីមេរោគហ៊ីវ/ជម្ងឺអេដស៍ (ICHA) ។*

### ៤-កម្មវិធីបន្តអភិវឌ្ឍ/វិក្រឹតការគ្រូបង្រៀន

- ផ្តោតការយកចិត្តទុកដាក់ទៅលើការបង្រៀនថ្នាក់គួប ជាពិសេសសម្រាប់សាលារៀនដែលស្ថិតនៅក្នុងតំបន់ដាច់ស្រយាល និងសាលារៀនមិនគ្រប់កំរិតថ្នាក់ ។ អាទិភាពត្រូវផ្តល់អោយគ្រូបង្រៀនដែលបច្ចុប្បន្នកំពុងបង្រៀនថ្នាក់គួប ។
- បង្កើនសមត្ថភាពគ្រូបឋមសិក្សា អោយទៅជាគ្រូមធ្យមសិក្សាបឋមភូមិ/គ្រូកំរិតអប់រំមូលដ្ឋាន ដើម្បីឆ្លើយតបទៅនឹងកំណើនសិស្សចូលរៀននៅមធ្យមសិក្សាបឋមភូមិ ។
- បំប៉នសមត្ថភាពស្តីពីការប្រើប្រាស់កម្មវិធីសិក្សាថ្មី សៀវភៅសិក្សាថ្មី និង ស្តង់ដាអប្បបរមានៃការសិក្សាជូនដល់គ្រូបង្រៀននៅគ្រប់កំរិតសិក្សា ។
- ផ្តល់ការបណ្តុះបណ្តាលបច្ចេកវិទ្យាព័ត៌មានសារគមនាគមន៍ (ICT) ដល់គ្រូឧទ្ទេស និងគ្រូមធ្យមសិក្សាទាំងអស់ ។
- ផ្តល់វិក្រឹតការដល់គ្រូបង្រៀន ស្តីពីសាលាកុមារមេត្រី និងកម្មវិធីសម្រាប់កុមារត្រៀមចូលរៀននៅបឋមសិក្សា ។
- ផ្តល់វគ្គបំប៉នបំណិនជីវិតស្តីពីមេរោគហ៊ីវ/ជម្ងឺអេដស៍ គាំទ្រដល់ការកែលំអគោលវិធីបង្រៀន[៨] ។

### ការគ្រប់គ្រង និង ការពិនិត្យតាមដានកម្មវិធី

គោលបំណងនៃកម្មវិធីនេះ គឺធ្វើវិមជ្ឈការការពិនិត្យតាមដាន និងការវាយតម្លៃដល់សាលាគរុកោសល្យ ស្តីពីការកសាងផែនការ និងត្រួតពិនិត្យបែបវិមជ្ឈការ ទៅជាការពិនិត្យតាមដាន និង ការគាំទ្រប្រព័ន្ធអប់រំគ្រូថ្នាក់ជាតិ ។ ការពិនិត្យតាមដាននឹងកំណត់អោយឃើញនូវឧទាហរណ៍នៃគំនិតផ្តួចផ្តើមថ្មីៗ និងការអនុវត្តល្អៗដែលក្រុមការងារពិនិត្យតាមដានថ្នាក់តំបន់របស់នាយកដ្ឋានបណ្តុះបណ្តាល និង វិក្រឹតការ ត្រូវប្រមូលចងក្រង ចែករំលែក និងផ្សព្វផ្សាយ ។ វត្ថុបំណងជាយុទ្ធសាស្ត្រនេះ គឺបង្កលទ្ធភាពផ្ទេរសិទ្ធិទទួលខុសត្រូវ និងស្វ័យភាពប្រតិបត្តិកាន់តែធំធេងដល់សាលាគរុកោសល្យ និង វិក្រឹតការខេត្ត-ក្រុង និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ។

ថវិកាសម្រាប់ដំណើរការគ្រឹះស្ថាននីមួយៗ ត្រូវបានផ្តល់ជូនតាមរយៈ BMCs ខេត្ត-ក្រុង និងនាយកដ្ឋានបណ្តុះបណ្តាល និង វិក្រឹតការ ។ នាយកដ្ឋានបណ្តុះបណ្តាល និង វិក្រឹតការ ត្រូវទទួលខុសត្រូវចំពោះការពិនិត្យតាមដាន និងការធានាគុណភាព ។ គណៈកម្មការបន្តការអភិវឌ្ឍគ្រូបង្រៀន ដែលស្ថិតនៅក្នុងនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ត្រូវទទួលខុសត្រូវចំពោះការកសាងផែនការ និងពិនិត្យតាមដានទូទៅ រួមមាន ការបែងចែកថវិកាទៅតាមសេចក្តីណែនាំដែលបានឯកភាពគ្នារួចហើយ ។ គណៈកម្មការបន្តការអភិវឌ្ឍគ្រូបង្រៀន ត្រូវផ្សារភ្ជាប់ទៅនឹងគណៈកម្មការកសាងផែនការរបស់សាលាគរុកោសល្យ និង វិក្រឹតការខេត្ត-ក្រុង និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ។ សាលាគរុកោសល្យ និង វិក្រឹតការខេត្ត-ក្រុង និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ

នីមួយៗ ត្រូវរៀបចំផែនការអភិវឌ្ឍន៍ប្រចាំឆ្នាំ និងរបាយការណ៍រីកចម្រើនប្រចាំត្រីមាសរៀងរាល់ឆ្នាំ ដើម្បីដាក់ជូនគណៈកម្មការបន្តការអភិវឌ្ឍគ្រូបង្រៀន ធ្វើការពិនិត្យឡើងវិញ និងផ្តល់ការយល់ព្រម ។

ការបែងចែកមូលនិធិទៅដល់សាលាគរុកោសល្យ និង វិក្រឹតការខេត្ត-ក្រុង មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ត្រូវគ្រប់គ្រងដោយអង្គភាពគ្រប់គ្រងថវិកា ដែលបង្កើតឡើងនៅក្នុងមន្ទីរអប់រំ យុវជន និង កីឡា ខេត្ត-ក្រុង ។ អង្គភាពគ្រប់គ្រងថវិកានេះ ត្រូវរៀបចំផែនការបែងចែកថវិកា និងទទួលខុសត្រូវធ្វើរបាយការណ៍កិច្ចបញ្ជិការគណនេយ្យស្តីពីការប្រើប្រាស់ថវិកា ។ គណៈកម្មការប្រើប្រាស់មូលនិធិរបស់សាលាគរុកោសល្យខេត្ត-ក្រុង រួមមាននាយក នាយករង តំណាងបុគ្គលិក ២ រូប និងតំណាងគរុសិស្ស-គរុនិស្សិត ២ រូប ។

នាយកដ្ឋានបណ្តុះបណ្តាល និង វិក្រឹតការ ទទួលខុសត្រូវចំពោះសកម្មភាពពិនិត្យតាមដានកម្មវិធី ដោយគិតទាំងការពិនិត្យតាមដានហិរញ្ញវត្ថុ ។ អង្គភាពគ្រប់គ្រងថវិការបស់នាយកដ្ឋានបណ្តុះបណ្តាល និង វិក្រឹតការ ទទួលខុសត្រូវចំពោះការគ្រោង និងការគ្រប់គ្រងអ្នកឯកទេស ធ្វើអង្កេត និងសវនកម្ម ដែលបានចុះកិច្ចសន្យាជាមួយនាយកដ្ឋានដទៃៗទៀតរបស់ក្រសួងអប់រំ យុវជន និង កីឡា ឬស្ថាប័នឯកជន ។ មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត-ក្រុង ត្រូវជួយធ្វើរបាយការណ៍ពិនិត្យតាមដានការរីកចម្រើន និងរបាយការណ៍ហិរញ្ញវត្ថុ ។ អគ្គនាយកដ្ឋានអប់រំ ត្រូវរៀបចំគំរូតាងសវនកម្មផ្នែកបច្ចេកទេស (sample technical audits) ចំណែកអគ្គាធិការដ្ឋានត្រូវរៀបចំគំរូតាងសវនកម្មហិរញ្ញវត្ថុផ្ទៃក្នុង (sample internal financial audits) ។

## ផែនការហិរញ្ញវត្ថុ

ផែនការផ្តល់ហិរញ្ញវត្ថុខាងក្រោមនេះ គឺគ្រាន់តែជាការបែងចែកថវិកាជាក់លាក់ និងដែលបានស្នើឡើងសម្រាប់សកម្មភាពនីមួយៗ ផ្អែកលើការវាយតម្លៃតម្រូវការប្រចាំឆ្នាំរបស់នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ដែលរួមមាន ការកែតម្រូវទៅលើក្រុមមុខសញ្ញាជាក់លាក់ ។

*តារាងទី៧ : ផែនការផ្តល់ហិរញ្ញវត្ថុចំពោះការបន្តការអភិវឌ្ឍគ្រូបង្រៀន*

| **សកម្មភាព** | **ចំណាយគិតជាលានរៀល** | | | | |
|---|---|---|---|---|---|
| | **2006** | **2007** | **2008** | **2009** | **2010** |
| ១- ថវិកាដំណើរការសម្រាប់សាលាគរុកោសល្យទាំង ២៥ ខេត្ត-ក្រុង | 4,650 | 4,700 | 5,200 | 5,200 | 5,200 |
| ២- កម្មវិធីអភិវឌ្ឍន៍បុគ្គលិកសាលាគរុកោសល្យ | 500 | 500 | 500 | 500 | 500 |
| ៣- កម្មវិធីអភិវឌ្ឍន៍ការគ្រប់គ្រងអប់រំ | 2,500 | 2,500 | 2,500 | 2,500 | 2,500 |
| ៤- កម្មវិធីការបន្តការអភិវឌ្ឍ/វិក្រឹតការគ្រូ | 2,820 | 2,845 | 3,250 | 3,250 | 3,250 |
| ៥- ការពិនិត្យតាមដាន និងការវាយតម្លៃ | 300 | 300 | 300 | 300 | 300 |
| **ធនធានសរុប** | **10,770** | **10,845** | **11,750** | **11,750** | **11,750** |

**តម្រូវការអភិវឌ្ឍសមត្ថភាព**

- សហការជាមួយនាយកដ្ឋានបុគ្គលិក គាំទ្រដល់ការរៀបចំប្រព័ន្ធគ្រប់គ្រង ដើម្បីវាយតម្លៃតម្រូវការ និងការផ្គត់ផ្គង់គ្រូបង្រៀនអោយកាន់តែមានប្រសិទ្ធភាព និងគាំទ្រដល់ដំណើរការកែលំអការជ្រើសរើស និងការដំឡើងឋានន្តរសក្តិ ។
- ពង្រឹងសមត្ថភាពគ្រប់គ្រងនៅគ្រប់សាលាគរុកោសល្យ ។
- បំប៉នគ្រូឧទ្ទេសនៅសាលាគរុកោសល្យទាំងអស់ ពីរបៀបប្រើប្រាស់ឧបករណ៍ពិសោធន៍មុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រ ។
- បំប៉នគ្រូឧទ្ទេសនៅសាលាគរុកោសល្យ ស្តីពីការអភិវឌ្ឍ និងប្រើប្រាស់សម្ភារឧបទ្ទេស ។
- ពង្រឹងសមត្ថភាពនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ដើម្បីកំណត់សកម្មភាពជាអាទិភាព ដើម្បីធ្វើអោយការផ្តល់សេវាកាន់តែមានប្រសិទ្ធភាព តាមរយៈសកម្មភាពដូចខាងក្រោម :
  - សហការជាមួយនាយកដ្ឋានបុគ្គលិក គាំទ្រដល់ការរៀបចំផែនការសកម្មភាពសម្រាប់បណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន ដើម្បីពង្រាយទៅកាន់សាលារៀននៅតំបន់ជនបទ តំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក ។
  - អភិវឌ្ឍផែនការសកម្មភាពសម្រាប់ពង្រីកការធ្វើវិក្រឹតការគ្រូបង្រៀន ។
  - វាយតម្លៃកម្មវិធីបណ្តុះបណ្តាល និង វិក្រឹតការគ្រូបង្រៀន រួមមានផលប៉ះពាល់នៃកម្មវិធីបណ្តុះបណ្តាលគ្រូសម្រាប់តំបន់ជនបទ តំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក ។
- បណ្តុះបណ្តាលគ្រូឧទ្ទេសនៅតាមសាលាគរុកោសល្យ ស្តីពីកម្មវិធីសាលាកុមារមេត្រី និងកម្មវិធីត្រៀមចូលរៀននៅបឋមសិក្សា ។